ASEM13 - PHNOM PENH - CAMBODIA

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
COUNCIL FOR THE DEVELOPMENT OF CAMBODIA

1st Asia Europe
Economic and Business Forum
Phnom Penh 2021

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃ " វេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ី-អឺរ៉ុបលើកទី១ (AEEBF1)"
# តាមរយៈប្រព័ន្ធវីដេអូ

...............

ក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណៈជន និងបណ្តាញព័ត៌មានឱ្យបានជ្រាបថា "**វេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ី-អឺរ៉ុប លើកទី១ (AEEBF1)**" បានរៀបចំឡើងតាមបែបរូបវន្ត និងប្រព័ន្ធវីដេអូ នៅ**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១** ដែលជាព្រឹត្តិការណ៍អមសំខាន់មួយនៃកិច្ចប្រជុំកំពូល ASEM13 ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះនៅឆ្នាំ២០២១។ វេទិកានេះ បានធ្វើឡើងក្រោមកិច្ចសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ,សភាពាណិជ្ជកម្មកម្ពុជា,សភាពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា, មូលនិធិអាស៊ី-អឺរ៉ុប(ASEF), ស្ថាប័នស្រាវជ្រាវ Bruegel និងដៃគូសហការដទៃទៀត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងមានការអញ្ជើញចូលរួមពីមន្ត្រីជាន់ខ្ពស់នៃស្ថាប័នរដ្ឋ បណ្តាអង្គទូតនៃប្រទេសសមាជិកអេសិម(ASEM) អ្នកធ្វើគោលនយោបាយ ក្រុមធុរជននិងវិនិយោគិន បញ្ញវន្ត អ្នកជំនាញការមកពីវិស័យសំខាន់ៗ និងអ្នកពាក់ព័ន្ធមកពីបណ្តាប្រទេសនៅអាស៊ី និងអឺរ៉ុប សរុបជាង ៥០០នាក់។

វេទិកានេះ បានធ្វើឡើងក្រោមមូលបទ "**ការផ្លាស់ប្តូរទៅរកគន្លងប្រក្រតីភាពថ្មី៖ ការធ្វើអានុភាវូបនីយកម្មខ្សែច្រវាក់តម្លៃសកល ពហុភាគីនិយម និងបដិវត្តឧស្សាហកម្ម ៤.០**" ហើយបានប្រព្រឹត្តទៅក្នុងបរិបទការរីករាលដាលនៃជំងឺកូវីដ-១៩ ក្នុងគោលបំណង " **ពង្រឹងពហុភាគីនិយម ដើម្បីកំណើនរួមគ្នា** " ដោយប្រមូលផ្តុំតួអង្គពាក់ព័ន្ធទាំងអស់ ធ្វើការពិភាក្សាស្វែងរកវិធីសាស្ត្រ និងមធ្យោបាយដោះស្រាយបញ្ហាប្រឈមនានាលើវិស័យសេដ្ឋកិច្ច និងសង្គមនៅក្នុងតំបន់អាស៊ីនិងអឺរ៉ុបក៏ដូចជាពិភពលោកទាំងមូល រួមគ្នាដើម្បីសម្រេចឱ្យបាននូវកំណើនប្រកបដោយបរិយាប័ន្ន។ ជាមួយនឹងការខិតខំប្រឹងប្រែងនេះ អាស៊ីនិងអឺរ៉ុបក៏បានលើកកម្ពស់ការធ្វើសកលភាវូបនីយកម្ម ខ្សែច្រវាក់តម្លៃសកល និងពហុភាគីនិយម ព្រមទាំងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព("SDGs") ជាពិសេសការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងការធ្វើធុរកិច្ច/វិនិយោគបៃតង ខណៈដែលពិភពលោកកំពុងឈានទៅរកបរិបទថ្មីនៃបដិវត្តឧស្សាហកម្ម៤.០ និងសម្របខ្លួនទៅនឹងការផ្លាស់ប្តូរទៅរកគន្លងប្រក្រតីភាពថ្មី ក្នុងបរិបទនៃជំងឺកូវីដ-១៩។

ដើម្បីសម្រេចបាននូវគោលបំណងខាងលើ វេទិកាសេដ្ឋកិច្ចនិងធុរកិច្ចអាស៊ី-អឺរ៉ុបលើកទី១ បានរៀបចំបទបង្ហាញចំនួន ៣ និងកិច្ចពិភាក្សាចំនួន ៣ ដែលក្នុងនោះវាគ្មិន និងអ្នកចូលរួមទាំងអស់បានចែករំលែកទស្សនៈ បទពិសោធន៍ ចំណេះដឹង និងការអនុវត្តល្អៗ ពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ទាំងវិស័យសាធារណៈ និងវិស័យឯកជន និងបានលើកជាអនុសាសន៍ ជូនដល់ថ្នាក់ដឹកនាំស្ថាប័នរដ្ឋ និងវិស័យឯកជន នៃប្រទេសសមាជិក ASEM ផងដែរ។

បទបង្ហាញទាំង ៣ រួមមាន៖ (១)ពហុភាគីនិយមនៃអង្គការពាណិជ្ជកម្មពិភពលោក៖ ការចូលរួមចំណែករបស់អាស៊ី និងអឺរ៉ុប (២)ភាពជាដៃគូអាស៊ី-អឺរ៉ុប សម្រាប់ខ្សែច្រវាក់តម្លៃសកល ប្រកបដោយចីរភាពក្នុងគន្លងប្រក្រតីភាពថ្មី

និង(៣)សេដ្ឋកិច្ចការទូតរវាងអាស៊ី និងអឺរ៉ុប៖ ក្បាលម៉ាស៊ីននៃកំណើន និងវិបុលភាព។ បទបង្ហាញទាំងនេះ បានផ្តោតខ្លឹមសារជាសារវន្ត ជុំវិញសារៈសំខាន់នៃពហុភាគីនិយម ដែលផ្សារភ្ជាប់នឹងការបង្កើតកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី និងពហុភាគី គឺនៅតែជាកត្តាគន្លឹះក្នុងការជំរុញអភិវឌ្ឍន៍សេដ្ឋកិច្ច និងកំណើន ដែលក្នុងនោះមានបដិវត្តឧស្សាហកម្ម៤.០, ឌីជីថលនីយកម្ម និងការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិកត្រូនិក ដែលបានជំរុញឱ្យមានផលិតភាពផលិតកម្ម, ភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច សម្រាប់សហគ្រាសមីក្រូ ធុនតូច និងមធ្យម ដែលជាឆ្អឹងខ្នងនៃការបង្កើតចំណូល និងការងារ ព្រមទាំងសហគ្រិនភាពសម្រាប់យុវជន និងស្ត្រីផងដែរ។

ដោយឡែក បទបង្ហាញទី២ បានឆ្លុះបញ្ចាំងពីកិច្ចខំប្រឹងប្រែងរួមគ្នារវាងអាស៊ី និងអឺរ៉ុប ដើម្បីដោះស្រាយបញ្ហាប្រឈម សំដៅធានាភាពធន់នៃខ្សែច្រវាក់តម្លៃ និងខ្សែច្រវាក់ផ្គត់ផ្គង់តំបន់ និងសកលលោក ដែលរួមចំណែកជាកម្លាំងចលករដល់ការអភិវឌ្ឍពាណិជ្ជកម្ម វិនិយោគ និងបង្កើតការងារ ពិសេសជំរុញឧស្សាហូបនីយកម្ម និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលតំបន់អាស៊ី និងអឺរ៉ុបចាំបាច់ត្រូវរួមដៃគ្នាអនុវត្ត សំដៅធានាកំណើនក្នុងបរិបទនៃសក្តានុពលពាណិជ្ជកម្មសកល ដែលពោរពេញដោយភាពធន់ ភាពប្រកួតប្រជែង ចីរភាព និងបរិយាប័ន្ន។ ក្នុងន័យនេះ ការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗ និងបញ្ញាសិប្បនិម្មិត គឺជាចំណុចផ្តើម និងជាមធ្យោបាយ ដែលភាគីពាក់ព័ន្ធទាំងអស់ រួមទាំងប្រទេសកំពុងអភិវឌ្ឍន៍ ចាំបាច់ត្រូវច្បាមយក សម្រាប់ជាឱកាសក្នុងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងបរិបទនៃបដិវត្តឧស្សាហកម្ម ៤.០ និងការផ្លាស់ប្តូរទៅរកគន្លងប្រក្រតីភាពថ្មី។

<u>កិច្ចពិភាក្សាទី១៖</u> ផ្តោតលើ " **ភាពរឹងមាំនៃបដិវត្តឧស្សាហកម្ម៤.០ និងភាពប្រសុីគ្នានៃពាណិជ្ជកម្មអាស៊ី និងអឺរ៉ុប អំឡុងពេលនៃជំងឺរាតត្បាតសកលកូវីដ-១៩**" ដើម្បី ៖

- ធានាឱ្យបានបរិយាកាស និងមូលដ្ឋានគ្រឹះនៃកំណើនប្រកបដោយបរិយាប័ន្ន ជាពិសេសក្នុងចំណោមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ តាមរយៈការប្រសុីគ្នារវាងការធ្វើពាណិជ្ជកម្ម និងកម្រិតអភិវឌ្ឍរវាងអាស៊ី និងអឺរ៉ុបក្នុងបរិបទពាណិជ្ជកម្ម និងវិនិយោគសកល ក្នុងបរិបទនៃការរីករាលដាលនៃជំងឺកូវីដ-១៩ ដោយប្រើប្រាស់អត្ថប្រយោជន៍នៃ បដិវត្តឧស្សាហកម្ម៤.០ ។
- បង្កើតស្ថាប័នជំនាញតាមកម្រិតនីមួយៗ ដើម្បីបញ្ជ្រៀបបដិវត្តឧស្សាហកម្ម៤.០ ប្រកបដោយប្រសិទ្ធភាពទៅក្នុងរបៀបវារៈពាណិជ្ជកម្ម និងវិនិយោគព្រមទាំងជួយសម្រួលដល់ធុរកិច្ចថ្មីៗ រួមទាំងសហគ្រាសធុនមីក្រូ ធុនតូច និងមធ្យមតាមរយៈការលើកទឹកចិត្តនិងកម្មវិធីផ្សេងៗ ដើម្បីទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបដិវត្តឧស្សាហកម្ម៤.០ ក្នុងគន្លងប្រក្រតីភាពថ្មី ។
- ប្តេជ្ញាចិត្តកិច្ចខិតខំប្រឹងប្រែងរួមគ្នា ត្រៀមលក្ខណៈរៀបចំកម្លាំងពលកម្ម និងរៀបចំរចនាសម្ព័ន្ធធុរកិច្ចឡើងវិញឱ្យល្អប្រសើរ ដើម្បីទទួលយកបច្ចេកវិទ្យា និងជំនាញថ្មីៗដែលត្រូវការចាំបាច់សម្រាប់បដិវត្តឧស្សាហកម្ម៤.០
- ពង្រីកកិច្ចសហប្រតិបត្តិការក្នុងតំបន់ និងអន្តរជាតិ ដើម្បីលើកកម្ពស់និងបញ្ជ្រាបការអភិវឌ្ឍប្រកបដោយចីរភាពធុរកិច្ចបៃតង និងបញ្ចូលរបៀបវារៈអភិវឌ្ឍន៍បៃតងទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីជំរុញឱ្យសេដ្ឋកិច្ចសកលប្រកបដោយចីរភាព និងភាពធន់ក្នុងរយៈពេលវែង។

<u>កិច្ចពិភាក្សាទី២៖</u> ផ្តោតលើ " **ការស្តារសេដ្ឋកិច្ចឡើងវិញក្នុងគន្លងប្រក្រតីភាពថ្មី និងបដិវត្តឧស្សាហកម្ម ៤.០៖ ការរួមបញ្ចូលពហុភាគីនិយម និងឌីជីថលនីយកម្ម**" ដើម្បី ៖

- បន្តពង្រឹងយន្តការពហុភាគីនិយមតាមរយៈក្របខណ្ឌផ្សេងៗគ្នា រួមទាំងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនៅកម្រិតផ្សេងៗ ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការវិស័យសេដ្ឋកិច្ច និងការអនុវត្តពាណិជ្ជកម្មសេរី ការវិនិយោគ និងភាព

ជាដៃគូរវាងប្រទេស និងតំបន់ដើម្បីកាត់បន្ថយការប៉ះពាល់ដែលកើតមានឡើងក្នុងបរិបទនៃការរីករាលដាលជំងឺកូវីដ-១៩ ។

- ផ្តោតសំខាន់លើភាពជាដៃគូយ៉ាងសកម្ម និងប្រទាក់ក្រឡាវាងរដ្ឋនិងឯកជន ក្នុងការលើកកម្ពស់ និងពង្រឹងយន្តការសកល និងពហុភាគី ។
- ផ្តល់នូវការអនុគ្រោះចាំបាច់ និងការលើកទឹកចិត្តនានា ដើម្បីលើកកម្ពស់ការចូលរួមរបស់សហគ្រាសធុនមីក្រូ ធុនតូច និងមធ្យម នៅក្នុងខ្សែច្រវាក់តម្លៃតំបន់និងសកល និងទាញយកអត្ថប្រយោជន៍ពីសក្តានុពលនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីវាងប្រទេស និងប្រទេស។

<u>កិច្ចពិភាក្សាទី៣៖</u> ផ្តោតលើ "**ការលើកកម្ពស់ខ្សែច្រវាក់តម្លៃ និងខ្សែច្រវាក់ផ្គត់ផ្គង់សកល " ដើម្បីកាត់បន្ថយបញ្ហាប្រឈមដែលជាផលប៉ះពាល់របស់ជំងឺកូវីដ១៩ នាពេលបច្ចុប្បន្ន " ដោយ ៖**

- លើកកម្ពស់ភាពជឿនលឿននៃខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃសកលតាមរយៈឌីជីថលនីយកម្ម និងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរចាំបាច់នានា ដើម្បីធានានូវភាពជឿជាក់នៃលំហូរពាណិជ្ជកម្មអន្តរជាតិ និងធានាឱ្យមានភាពធន់ ព្រមទាំងដំណោះស្រាយបញ្ហាប្រឈម ដែលប៉ះពាល់ដល់ការផ្គត់ផ្គង់និងតម្រូវការពិភពលោក។
- បង្កើតក្របខណ្ឌគាំទ្រចាំបាច់នានាដើម្បីជំរុញគំរូថ្មីនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃសកលដែលកំពុងលេចធ្លោរួមមាន៖ ការប្រគល់ទទួល-ទំនិញពីចម្ងាយ ការបង្កិតជិតគ្នានៃធុរកិច្ច ប្រតិបត្តិការអន្តរតំបន់ ការសម្របខ្លួនតាមបរិបទតំបន់ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធបៃតង ដើម្បីជំរុញល្បឿនពាណិជ្ជកម្មសកលឡើងវិញខណៈពេលដែល ពិភពលោកបានងើបឡើងវិញពីវិបត្តិកូវីដ-១៩។
- ផ្តល់ការលើកទឹកចិត្ត និងជំនួយចាំបាច់នានា សម្រាប់សហគមន៍ធុរកិច្ច និងឧស្សាហកម្មក្នុងការបម្លែងខ្លួនទៅជាធុរកិច្ចបៃតង ដើម្បីទាញយកផលប្រយោជន៍ពីទំនើបកម្មនៃខ្សែច្រវាក់ផ្គត់ផ្គង់ និងខ្សែច្រវាក់តម្លៃសកលដោយប្រើបច្ចេកវិទ្យានាពេលអនាគត។

"**វេទិកាសេដ្ឋកិច្ច និងធុរកិច្ចអាស៊ី-អឺរ៉ុប លើកទី១**(AEEBF1)" **នេះ** បានប្រព្រឹត្តទៅយ៉ាងរលូន និងទទួលបានលទ្ធផលប្រកបដោយផ្លែផ្កាគួរជាទីមោទនៈ ក្នុងន័យជំរុញកំណើនសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ និងការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន សម្រាប់ប្រជាជាតិយើងទាំងអស់។

ថ្ងៃពុធ ៥រោច ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២១

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងពាណិជ្ជកម្ម

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទូរសព្ទ/ទូរសារ៖ (៨៥៥) ២៣ ៨៦៦ ៤៦៩
Lot 19-61 Russian Federation Blvd., Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Fax: (855) 23 866 469